# English for Study in Australia

# ភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 3 – Make yourself at home

## *មេរៀនទី៣៖ សម្រួលអារម្មណ៍និងរៀបចំខ្លួនឲ្យដូចជាការឋិតនៅក្នុងផ្ទះខ្លួនឯងផ្ទាល់*

**STUDY NOTES**

ឯកសារជំនួយមេរៀន

**<u>Characters</u>**

<u>តួអង្គ</u>

Katie: ជានិស្សិតស្រីមកប្រទេសអូស្ត្រាលីជាលើកទីមួយ

ខេតធី៖

Jenny: ស្ត្រីជាមេគ្រួសារ និងម្ចាស់ផ្ទះ ដែលខេតធីស្នាក់នៅជាមួយ។

ជេន្នី៖

<u>សាច់រឿង</u>

ខេតធី មកដល់ផ្ទះគ្រួសារជនជាតិអូស្ត្រាលីដែលនាងស្នាក់នៅជាមួយ។ ស្ត្រីម្ចាស់ឈ្មោះ ជេន្នីធ្វើការស្វាគមន៍ និងនាំនាងដើរមើលក្នុងផ្ទះ។

<u>ព័ត៌មាន ៖ ទម្លាប់និងវិន័យសំខាន់មួយចំនួនសម្រាប់ការស្នាក់នៅផ្ទះជាមួយជនជាតិអូស្ត្រលី</u>

- ត្រូវនិយាយពាក្យថា “please” នៅពេលលោកអ្នកស្នើសុំអ្វីមួយ។
- ត្រូវនិយាយថា “thank you” បន្ទាប់ពីលោកអ្នកទទួលជំនួយ ឬព័ត៌មានអ្វីមួយ។
- ត្រូវនិយាយប្រាប់ម្ចាស់ផ្ទះ បើលោកអ្នកមានបញ្ហាអ្វីមួយ។
- នៅពេលលោកអ្នកចេញទៅក្រៅ ត្រូវ ជូនដំណឹងដល់ម្ចាស់ផ្ទះ អំពី កន្លែងដែលលោកអ្នកត្រូវទៅ មនុស្សដែលលោកអ្នកនឹងទៅជាមួយ និងម៉ោងពេលលោកអ្នកនឹងត្រឡប់មកផ្ទះវិញ ។
- សូមត្រឡប់មកផ្ទះ នៅពេលណាដែលលោកអ្នកប្រាប់ថានឹងត្រឡប់មកវិញ។
- ទូរស័ព្ទប្រាប់សមាជិកគ្រួសារដែលអ្នកស្នាក់នៅជាមួយ ប្រសិនបើលោកអ្នកនឹងត្រឡប់មកផ្ទះវិញយឺត។
- ចូរស្វែងយល់ថាតើ លោកអ្នកអាចអញ្ជើញមិត្តភក្តិមកលេងផ្ទះបានឬទេ។ ត្រូវជូនដំណឹងដល់សមាជិកគ្រួសារម្ចាស់ផ្ទះ ប្រសិនបើមានមិត្តភក្តិមកលេង។


© RadioAustralia/AMES 2008

- ប្រសិនបើលោកអ្នកមានភារកិច្ចប្រគល់ថ្លៃចំណាយផ្សេងៗ ដល់ម្ចាស់ផ្ទះ លោកអ្នកត្រូវប្រគល់ប្រាក់ទាំងនោះឱ្យទាន់ពេលវេលា។
- បូមធូលី និងសម្អាតធូលីក្នុងបន្ទប់ ព្រមទាំគ្រឿងសង្ហារឹមផ្សេងៗ ជារៀងរាល់សប្តាហ៍ ហើយត្រូវយកសំរាមចាក់ចោល។
- ប្រសិនបើលោកអ្នកមានភារកិច្ចបោកគក់សម្លៀកបំពាក់ផ្ទាល់ខ្លួន សូមធ្វើការបោកគក់ប្រចាំសប្តាហ៍។
- ជានិច្ចកាលត្រូវបិទទ្វារ និងវាំងនន នៅពេលលោកអ្នកគេង ឬស្លៀកពាក់។
- នៅពេលថ្ងៃ ត្រូវបើកបង្អួចដើម្បី ឱ្យមានខ្យល់អាកាសចេញចូល ក្នុងពេលលោកអ្នកនៅក្នុងបន្ទប់ ប៉ុន្តែត្រូវបិទ និងចាក់សោទ្វារបង្អួច រាល់ពេលលោកអ្នកចេញពីផ្ទះ។
- ការបិទទ្វារឮសូរខ្លាំងៗ គឺជាទង្វើដែលមិនសមរម្យ។ ជានិច្ចកាល លោកអ្នកត្រូវកាន់ដៃទ្វារនៅពេលទាញទ្វារបិទថ្នមៗ។

<u>ភាសា</u>

ខាងក្រោមនេះ ជាសំនួនវោហារ និងឃ្លាមានន័យមិនធម្មតាខ្លះៗដែលលោកអ្នកអាចនឹងឮនៅពេលលោកអ្នកស្នាក់នៅក្នុងគ្រួសារជនជាតិអូស្ត្រាលី។

| | |
|---|---|
| Make yourself at home<br>Make yourself comfortable | ឃ្លា "Make yourself at home" គឺមានន័យថា សម្រួលអារម្មណ៍និងរៀបចំខ្លួនឲ្យដូចជានៅក្នុងផ្ទះខ្លួនឯងផ្ទាល់។ ត្រូវមានអារម្មណ៍សុខស្រួលហាក់ដូច ជាលោកអ្នកនៅផ្ទះរបស់លោកអ្នកអីចឹងដែរ។ |
| Help yourself | ឃ្លា "Help yourself" គឺមានន័យថា លោកអ្នកអាចយក និងប្រើប្រាស់របស់របរបានដោយខ្លួនឯង។ ឧទាហរណ៍ Help yourself to food សូមយកចំណីអាហារហូបទៅតាមសម្រួលដោយខ្លួនឯងចុះ។ |
| Feel free | ឃ្លា "Feel free" គឺមានន័យថា លោកអ្នកអាចធ្វើអ្វីមួយដោយមិនបាច់សួរខ្ញុំសាជាថ្មីទេ។ ឧទាហរណ៍ Feel free to invite your friends over អ្នកអាចអញ្ជើញមិត្តភក្តិអ្នកមកលេងបានដោយកុំទើសទាល់អ្វី។ |
| You'll get the hang of it | ឃ្លា "You'll get the hang of it" គឺមានន័យថា លោកអ្នកនឹង រៀនសូត្រ យល់ដឹងអំពីរបៀបរបបដែលយើងរស់នៅ។ |
| Yell out<br>Sing out | ឃ្លា "Yell out" និង "Sing out" គឺមានន័យថា លោកអ្នកអាចសាកសួរអ្វីដែលលោកអ្នកត្រូវការ ដោយមិនចាំបាច់មានការថប់ |


© RadioAustralia/AMES 2008

| | |
|---|---|
| | បារម្ភអ្វីឡើយ។<br>(លោកអ្នកមិនចាំបាច់ស្រែក ឬហៅឡើយ) |
| A cuppa | តែ (ឬកាហ្វេ) មួយពែង។ |

**EXERCISES**
លំហាត់

១ វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក។

| | | |
|---|---|---|
| basket | bathroom | conscious |
| cupboard | desk | dirty |
| doona | (to) freshen up | friendly |
| garage | hall | (to) store |
| towel | (to) unpack | wardrobe |

២ ការហាត់រៀនភាសា៖ លំហាត់គំរូ - *តេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស*

ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ គឺលោកអ្នកចាំបាច់ត្រូវធ្វើតេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word that best fits each space in the text below.


© RadioAustralia/AMES 2008

**Water Restrictions**

Water restrictions apply across Australia. States have different levels of restrictions.
In the state of Victoria, major restrictions __(1)__. For example, people __(2)__ wash their cars or water their lawns. They can water their gardens only __(3)__ certain times during the week. People in Australia are very aware of saving water. They have quick showers and make sure they turn off all dripping taps. They wait __(4)__ a full load before they use the washing machine. They even turn off the tap __(5)__ they're brushing their teeth. And you might find a bucket in the shower. That's to catch your excess shower water, which can still be used __(6)__ the garden.

សូមគូសខ្វែងមួយក្នុងប្រអប់នៃពាក្យនីមួយៗ។ ឧទាហរណ៍ ☒ of

| | | | |
|---|---|---|---|
| (1) | ☐ apply | ☐ applies | ☐ applying |
| (2) | ☐ aren't | ☐ cannot | ☐ not |
| (3) | ☐ at | ☐ on | ☐ by |
| (4) | ☐ about | ☐ before | ☐ for |
| (5) | ☐ while | ☐ with | ☐ since |
| (6) | ☐at | ☐ on | ☐ from |

ABC Radio Australia

៣ ឧបសគ្គក្នុងការប្រើប្រាស់ភាសា

សូសំឡេង/V/ ៖ សូមហាត់រៀនថាតាមសូរស័ព្ទដ៏លំបាកនេះដោយការបញ្ចេញសម្លេងឱ្យឮៗ។

**'We have a lovely view of the river.'**

៤ អាសយដ្ឋានអ៊ីនធើរណិតដែលមានប្រយោជន៍

| | |
|---|---|
| កន្លែងស្នាក់នៅទូទៅ | http://www.services.unimelb.edu.au/housing/options/private.html |
| ផ្ទះស្នាក់នៅជាមួយជនជាតិអូស្ត្រាលី | http://www.services.unimelb.edu.au/housing/downloads/Homestay_Jan05.pdf |
| គំរូកន្លែងស្នាក់នៅក្នុងមហាវិទ្យាល័យ | http://www.services.unimelb.edu.au/housing/options/affiliated.html |


© RadioAustralia/AMES 2008

| | |
|---|---|
| កន្លែងស្នាក់នៅរួមគ្នា និង កន្លែងស្នាក់នៅសម្រាប់ជួល | http://www.realestate.com.au/cgi-bin/rsearch?s=vic&t=res&snf=rbs&a=sf |
| ពាក្យកាត់នៃអចលនទ្រព្យ | http://www.services.unimelb.edu.au/housing/downloads/RealEstateSpeak_Jan05.pdf |

ចម្លើយលំហាត់ទី២: 1) apply 2) cannot 3) at 4) for 5) while 6) on

ABC Radio Australia


© RadioAustralia/AMES 2008